**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

**សូមគោរពជូន**

**សម្ដេចពិជ័យសេនា ទៀ បាញ់**

**ឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីចម្រើនជន្មាយុ**

***សម្ដេចពិជ័យសេនា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយសេចក្ដីសោមនស្សរីករាយក្រៃលែង នៃពិធីចម្រើនជន្មាយុ **សម្ដេច** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ៧រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំបាទនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្ដី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **សម្ដេច** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងកាយមាំមួន ប្រាជ្ញាឈ្លាសវៃ ជន្មាយុយឺនយូរ ។

ឆ្លៀតក្នុងឱកាសដ៏មហាប្រសើរនេះផងដែរ ខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នា សូមសម្ដែងនូវសេចក្ដីគោរព និងការនឹករលឹកយ៉ាងជ្រាលជ្រៅបំផុតមិនអាចបំភ្លេចបានចំពោះសកម្មភាពប្រកបដោយគំរូវីរភាពដ៏មោះមុតរបស់ **សម្ដេច** ដែលកន្លងមកតែងបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតីក្នុងការបម្រើជាតិមាតុភូមិឱ្យមានសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍតាមរយៈនយោបាយឈ្នះ ឈ្នះ របស់រាជរដ្ឋាភិបាល ពិសេសក្រោមការដឹកនាំរបស់ **សម្ដេច** បានធ្វើឱ្យស្ថាប័នក្រសួងការពារជាតិមានភាពរឹងមាំ ខ្លាំងក្លា រក្សាបាននូវសន្តិភាព ឯករាជ្យភាព និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមគ្នានេះដែរ ខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នាសូមសម្ដែងនូវមោទនភាព និងក្ដីអំណរសាទរចំពោះ **សម្ដេច** ដែលត្រូវបាន **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង** ត្រាស់បង្គាប់តែងតាំងជាឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។

ជាថ្មីម្ដងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមខ្ញុំបាទនិងភរិយា សូមលើកហត្ថបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្ដិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះអង្គតាមជួយបីបាច់ថែរក្សាព្រោះព្រំសព្ទសាធុការពរជ័យជូន **សម្ដេចពិជ័យសេនា** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រីជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្ដេចពិជ័យសេនា ទៀ បាញ់ ឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

ថ្ងៃចន្ទ ៤រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្ដមសេនីយ៍ **ទៀ សីហា**